**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្ត**
**កំពត**

**តាងនាមប្រជារាស្ត្រខ្មែរ**

**សំណុំរឿងព្រហ្មទណ្ឌលេខ: ៥៩៧**
ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩
សំណុំរឿងស៊ើបសួរលេខ ៣៦៩
ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩
សំណុំរឿងជំនុំជម្រះលេខ ៥២
ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២០
**សាលក្រមព្រហ្មទណ្ឌលេខ ២១៩ "ខ"**
ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០

បានបើកសវនាការជាសាធារណៈនៅសាលសវនាការ នៃសាលាដំបូងខេត្តកំពត។
កាលបរិច្ឆេទបើកសវនាការថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ ។
កាលបរិច្ឆេទប្រកាសសាលក្រមថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ ។

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ក្រុមប្រឹក្សាជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូង ខេត្តកំពត

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូង ខេត្តកំពត

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ៥៩៧ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ៖ ឈ្មោះ [redacted]ស៊ិន ហៅសាយ ភេទប្រុស អាយុ ៥៥ឆ្នាំ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបររត់ម៉ូតូឌុប កើតនៅ[redacted] ខេត្តកំពត និងទីលំនៅបច្ចុប្បន្ននៅភូមិលក ឃុំឫស្សីស្រុកខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត ឪពុកឈ្មោះ [redacted] ឈិ (ស្លាប់), ម្ដាយឈ្មោះ [redacted]ញ៉ (ស្លាប់), ប្រពន្ធឈ្មោះ [redacted] ប៉ុ មានកូន ០៥នាក់ ជានីតិជន ទោសពីមុន គ្មាន ។ (ក្នុងឃុំ)

ដោយមានលោក [redacted] ជាមេធាវីការពារក្ដី ។

ត្រូវបានចោទប្រកាន់ពីបទ រំលោភសេពសន្ថវៈ, សមគំនិត និងការនាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន ប្រព្រឹត្តនៅភូមិស្រុកហាទៀង ខេត្តគៀនយ៉ាង ប្រទេសវៀតណាម កាលពីថ្ងៃទី១៩-២០ ខែសីហា ឆ្នាំ២០១៩ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា២៩ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៨, ១១ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

Scanned with CamScanner

តាមដីកាដំណោះស្រាយលេខ ៥៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពត។

## ដើមបណ្តឹង និងជនរងគ្រោះ

.ឈ្មោះ [redacted] ស្រីមៅ ហៅពេជ្រ ភេទស្រី អាយុ ២២ឆ្នាំ ជនជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិព្រៃទីទុយ សង្កាត់ព្រែស ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

.ឈ្មោះ [redacted] សារ៉ាន ភេទស្រី អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិទួលកកោះ សង្កាត់ព្រែស ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

## អង្គហេតុមានដូចតទៅ:

កាលពីថ្ងៃទី១៩-២០ ខែសីហា ឆ្នាំ២០១៩ ស្ថិតនៅស្រុកហាទៀង ខេត្តគៀនយ៉ាង ប្រទេសវៀតណាម មានករណី រំលោភសេពសន្ថវៈ សមគំនិត និងការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន មួយបានកើតឡើង ដែលបង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] ភេទស្រី អាយុប្រហែល ៦០ឆ្នាំ និងឈ្មោះ [redacted] ស៊ុន ហៅសាយ ភេទប្រុស អាយុ ៥៥ឆ្នាំ ដោយជនសង្ស័យបាននាំជនរងគ្រោះឈ្មោះ [redacted] សារ៉ាន ភេទស្រី អាយុ ២៧ឆ្នាំ និងឈ្មោះ ស្រីមៅ ភេទស្រី អាយុ ២២ឆ្នាំ ទៅកាន់ប្រទេសវៀតណាមហើយសន្យាថា នឹងបន្តទៅប្រទេសចិន ដើម្បីធ្វើការ ប៉ុន្តែក្រោយពីបានដឹកជនរងគ្រោះដាក់ផ្ទះសំណាក់នៅប្រទេសវៀតណាម ខេត្តគៀនយ៉ាង ជនសង្ស័យឈ្មោះ [redacted] ស៊ុន ហៅសាយ ភេទប្រុស អាយុ ៥៥ឆ្នាំ បានទៅជួបជនរងគ្រោះឈ្មោះ [redacted] សារ៉ាន ហើយបានលួងលោមជនរងគ្រោះថានឹងជួយជូនទៅផ្ទះនៅប្រទេសកម្ពុជា ដោយគ្រាន់តែយល់ព្រមរួមភេទជាមួយខ្លួន ប៉ុន្តែក្រោយរួមភេទហើយ ឈ្មោះ [redacted] ស៊ុន ហៅសាយ ក៏បិទទូរស័ព្ទ និងគេចវេសពីឈ្មោះ [redacted] សារ៉ាន រហូតជនរងគ្រោះប្តឹងសមត្ថកិច្ចប្រទេសវៀតណាមតែម្តង ។ ក្រោយពេលកើតហេតុជនរងគ្រោះបានទៅប្តឹងសមត្ថកិច្ចដើម្បីជួយអន្តរាគមន៍ សមត្ថកិច្ចក៏បានធ្វើការស្រាវជ្រាវ និងឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] ស៊ុន ហៅសាយ ភេទប្រុស អាយុ ៥៥ឆ្នាំ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៩ រួចបញ្ជូនមកកាន់អយ្យការអមសាលាដំបូងខេត្តកំពត ដើម្បីចាត់ការតាមនីតិវិធី ។ ចំណែកឈ្មោះ [redacted] ភេទស្រី អាយុប្រហែល៦០ឆ្នាំ បានគេចខ្លួនទៅប្រទេសវៀតណាមបាត់ ។

## នាពេលសវនាការក្រោយពីបាន

- ស្តាប់ចម្លើយរបស់ជនជាប់ចោទ
- ស្តាប់អំណានចម្លើយដើមបណ្តឹង
- ស្តាប់អំណានឯកសាររបាយការណ៍ និងកំណត់ហេតុផ្សេងទៀតដែលមានក្នុងសំណុំរឿង
- ស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
- ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ពិនិត្យភស្តុតាងនិងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

១.កាលពីថ្ងៃទី១៩-២០ ខែសីហា ឆ្នាំ២០១៩ មានអំពើ រំលោភសេពសន្ថវៈ, សមគំនិត និងការនាំចេញដោយមិនស្រប ច្បាប់សម្រាប់ឆ្លងដែន ប្រព្រឹត្តនៅភូមិស្រុកហាទៀង ខេត្តគៀនយ៉ាង ប្រទេសវៀតណាម ប្រាកដមែន ។

២.តាមដីកាដំណោះស្រាយលេខ ៥៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ និងតាមដីកាសន្និដ្ឋានស្ថាពរលេខ២១ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ របស់តំណាងអយ្យការចោទប្រកាន់ឈ្មោះ [redacted] ស៊ិន ហៅសាយ ភេទប្រុស អាយុ ៥៥ឆ្នាំ ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ មុខរបររត់ម៉ូតូឌុប ពីបទ រំលោភសេពសន្ថវៈ, សមគំនិត និងការនាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន ប្រព្រឹត្តនៅភូមិស្រុកហាទៀង ខេត្តគៀនយ៉ាង ប្រទេសវៀតណាម កាលពីថ្ងៃទី១៩-២០ ខែសីហា ឆ្នាំ២០១៩ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៩ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៨,១១ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើ ជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

៣.តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ស៊ិន ហៅសាយ បានឆ្លើយនាពេលសវនាការថា គេហៅខ្លួនឲ្យជួយដឹកគេផងចូលតាមច្រកព្រំដែន ពេលនោះខ្លួនបានឲ្យកូនស្រីខ្លួនជាអ្នកដឹកស្រី ២នាក់នោះ ហើយខ្លួនបានឲ្យលេខទូរសព្ទ ហើយខ្លួនបាននិយាយប្រាប់ពីការរស់នៅស្រុកគេ ហើយក៏បានហូបកាហ្វេ ពេលនោះនិយាយត្រូវគ្នា ហើយបានឡើងផ្ទះសំណាក់ ខ្លួនបានរួមភេទជាមួយឈ្មោះ [redacted] សារ៉ាត់ ម្ចាស់ផ្ទះសំណាក់ឈ្មោះយាយវ៉ាង ឲ្យដឹកចេញក្នុងម្នាក់ ៥០ម៉ឺនដុងឈ្មោះ [redacted] ស្រីមៅ និងឈ្មោះ [redacted] សារ៉ាន ខ្លួនបានរួមភេទជាមួយឈ្មោះ [redacted] សារ៉ាន បានប្រហែលមួយម៉ោងទើបបានរួច ពេលផឹកកាហ្វេហើយទើបរួមភេទ ខ្លួនឲ្យលុយចំនួន១៥ម៉ឺនដុងទៅឈ្មោះ [redacted] សារ៉ានទុកមកវិញ។ ដឹកទៅវៀតណាមដោយម្ចាស់ផ្ទះសំណាក់គេឲ្យដឹកឲ្យគេ ពេលនោះខ្លួនឲ្យកូនស្រីជាអ្នកដឹក ពេលព្រឹកឡើងខ្លួនទើបបានជួបហើយខ្លួនសួរថា ទៅណាគេថា ទៅវៀតណាម ខ្លួនបានឲ្យលេខទូរសព្ទដើម្បីទំនាក់ទំនងមកខ្លួនពេលចេញមកវិញ ពេលដែលនិយាយត្រូវគ្នាក៏បានចូលក្នុងផ្ទះសំណាក់ ។ ខ្លួនរត់ម៉ូតូឌុប និងចាក់មេក្រូឈ្មោះយាយ វ៉ាងហៅខ្លួនឲ្យដឹកឲ្យគេ ខ្លួនបានតំលៃ៥០ម៉ឺនដុង ស្មើ៨ម៉ឺនរៀល ចេញពីកាស់ស៊ីណូថ្មី ខ្លួនមិនដឹងថាគេធ្វើអ្វីទេ ខ្លួនដឹកស៊ីឈ្នួល ៥ឆ្នាំហើយ ពេលឡើងផ្ទះសំណាក់ខ្លួនមិនគំរាមគំហែងទេ ខ្លួនសន្យាថាយកគ្នាជាប្តីប្រពន្ធ ខ្លួនមិនបានទទួលកំរៃពីការជួញដូរមនុស្សទេ ។

.តាមអំណានចម្លើយដើមបណ្តឹងឈ្មោះ [redacted] ស្រីមៅ ហៅពេជ្រ និងឈ្មោះ [redacted] សារ៉ាន នាពេលសវនាការថា នៅក្នុងរឿងនេះខ្លួនពុំដែលស្គាល់អ្នកណាទាំងអស់ ខ្លួនតាមតែមីងរបស់ខ្លួនទេ ខ្លួនមិនដែលស្គាល់មេខ្យល់នោះទេ ពេលខ្លួន និងមីងរបស់ខ្លួនទៅធ្វើប៉ាស្ព័រ មានស្រីម្នាក់គេមកលេខទូរស័ព្ទប្អូនប្រុសរបស់ខ្លួនពិតមែន តែខ្លួនមិនដែលស្គាល់ស្រីម្នាក់នោះទេ មនុស្សប្រុសដែលនាំខ្លួនទៅធ្វើប៉ាស្ព័រ ខ្លួនអត់ស្គាល់គាត់ទេ ហើយតែកុងឡានក៏អត់ស្គាល់ដែរ ពួកខ្លួនប្តឹងសមត្ថកិច្ច

វៀតណាមដោយគ្រាន់តែចង់ត្រឡប់មកស្រុកខ្មែរវិញតែប៉ុណ្ណោះ ពេលនេះខ្លួនឈប់ប្តឹងតទៅទៀត ហើយ សុំដកពាក្យបណ្តឹងវិញ គប្បីតុលាការពិចារណា ។

៤.តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋាន ក្រោយពីបានសួរដេញដោល ស្តាប់អំណាន ចម្លើយដើមបណ្តឹងនិងរបាយការណ៍របស់សមត្ថកិច្ចរួចមកឃើញថា ជនជាប់ចោទឈ្មោះ [redacted] ស៊ុន ហៅសាយ ពិតជាបានប្រព្រឹត្ត រំលោភសេពសន្ថវៈ, សមគំនិត និងការនាំចេញ ដោយមិនស្រប ច្បាប់សម្រាប់ឆ្លងដែនប្រព្រឹត្តនៅស្រុកហាទៀង ខេត្តគៀងយ៉ាង ប្រទេសវៀតណាម កាលពីថ្ងៃទី១៩ .២០ខែសីហា ឆ្នាំ២០១៩ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៩.២៣៩ នៃ ក្រមព្រហ្មទណ្ឌ និងមាត្រា៨.១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវ ភេទ។ ដូច្នេះតំណាងអយ្យការតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ២១ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ ទុកជា បានការដដែលប្តឹងសុំឲ្យតុលាការសម្រេចតាមច្បាប់ គប្បីតុលាការពិចារណា ។

.មេធាវីបានធ្វើសេចក្តីសន្និដ្ឋានការពារ ក្រោយពីបានសួរដេញដោល ស្តាប់អំណាន ចម្លើយដើមបណ្តឹងនិងសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការរួចមកឃើញថា កូនក្តីខ្លួនបានទំនាក់ ទំនងជាមួយឈ្មោះ [redacted] សារ៉ាន ហើយបានត្រូវគ្នាក៏បានឡើងផ្ទះសំណាក់រួមភេទជាមួយគ្នា ការរួម ភេទនេះគឺតាមការព្រមព្រៀងគ្នា កូនក្តីខ្លួនមិនបានបង្ខិបង្ខំទេ ម្យ៉ាងទៀតកូនក្តីខ្លួនជាអ្នករកស៊ី រត់ម៉ូតូឌុប បើមានគេហៅឲ្យឌុបគឺកូនក្តីខ្លួនឌុបយកកំរៃបាន៥០ម៉ឺនដុង ហើយក្នុងហេតុការណ៍ជន រងគ្រោះក៏បានដកពាក្យបណ្តឹងផងដែរ ហើយសុំឲ្យប្រធានក្រុមប្រឹក្សាសម្រេចឲ្យកូនក្តីខ្លួនរួចផុត ពីបទចោទ គប្បីតុលាការពិចារណា ។

៥.ជនជាប់ចោទឈ្មោះ[redacted] ស៊ុន ហៅសាយ និងជនរងគ្រោះឈ្មោះ[redacted] សារ៉ាន ពិតជាបាន ព្រមព្រៀងគ្នាឡើងផ្ទះសំណាងដើម្បីរួមភេទជាមួយគ្នាតែប៉ុណ្ណោះ ពុំមានភស្តុតាងណាបញ្ជាក់ថា ឈ្មោះ[redacted] ស៊ុន បានប្រព្រឹត្តអំពើរំលោភសេពសន្ថវៈនោះឡើយ គប្បីតុលាការឲ្យរួចផុតពីបទ រំលោភសេពសន្ថវៈ តាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ។

៦.ជនជាប់ចោទឈ្មោះ[redacted] ស៊ុនហៅសាយ ពិតជាបានប្រព្រឹត្តអំពើសមគំនិត និងការនាំ ចេញដោយមិន ស្របច្បាប់សម្រាប់ឆ្លងដែន ដោយចេតនាប្រាកដមែន ពេលប្រព្រឹត្តបទល្មើសជន ជាប់ចោទមាន ស្មារតីគ្រប់គ្រាន់នូវអំពើរបស់ខ្លួន ។

៧.អំពើល្មើសរបស់ជនជាប់ចោទប្រព្រឹត្តមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៩នៃក្រមព្រហ្ម ទណ្ឌ និងមាត្រា៨,១១ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវ កម្មផ្លូវភេទ ។

៨.ជនជាប់ចោទគ្រាន់តែជាអ្នករត់ម៉ូតូឌុប ដើម្បីយកកំរៃតាមការប្រាប់ និងណែនាំរបស់ ឈ្មោះយាយវ៉ាង និងជនជាប់ចោទជាមនុស្សចាស់អាយុ៥៥ឆ្នាំហើយ ដូច្នេះតុលាការគប្បីសម្រាល ទោសដល់ជនជាប់ចោទដោយអនុលោមតាមមាត្រា៩៣.៩៤ នៃក្រមព្រហ្មទណ្ឌ ។

៩.គ្មានភស្តុតាង និងគ្មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ស៊ុន ហៅសាយ ជនជាតិខ្មែរ ពីបទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិស្រុកហាទៀង ខេត្តគៀនយ៉ាង ប្រទេសវៀត

Scanned with CamScanner

ណាម កាលពីថ្ងៃទី១៩-២០ ខែ សីហា ឆ្នាំ២០១៩ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោស មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ។

១០.មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ស៊ុន ហៅសាយ ជនជាតិខ្មែរ ពីបទសមគំនិត និងការនាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន ប្រព្រឹត្តនៅភូមិស្រុកហាទៀង ខេត្តគៀនយ៉ាង ប្រទេសវៀតណាម កាលពីថ្ងៃទី១៩-២០ ខែសីហា ឆ្នាំ២០១៩ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៨,១១ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

**ដូច្នេះសម្រេច**

១.ឲ្យជនជាប់ចោទឈ្មោះ [redacted] ស៊ុន ហៅសាយ ភេទប្រុស អាយុ ៥៥ឆ្នាំ ជាតិខ្មែរ (ឃុំខ្លួន)រួចផុតបទចោទប្រកាន់បទ រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិស្រុកហាទៀង ខេត្តគៀនយ៉ាងប្រទេសវៀតណាម កាលពីថ្ងៃទី១៩-២០ ខែសីហា ឆ្នាំ២០១៩ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌ ។

២.ផ្តន្ទាទោសៈឈ្មោះ [redacted]ស៊ុន ហៅសាយ ភេទប្រុស អាយុ៥៥ឆ្នាំ ជាតិខ្មែរ (ឃុំខ្លួន) ដាក់ពន្ធនាគារកំណត់ ០៤ឆ្នាំ (បួនឆ្នាំ) តែទោសអនុវត្តក្នុងពន្ធនាគារ០២ឆ្នាំ(ពីរឆ្នាំ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ ទោសនៅសល់ពីនេះព្យួរសាកល្បងរយៈពេល០៣ឆ្នាំ ដោយអនុលោមតាមមាត្រា៩៣.៩៤ នៃក្រមព្រហ្មទណ្ឌ ពីបទ សមគំនិត និងការនាំចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន ប្រព្រឹត្តនៅភូមិស្រុកហាទៀង ខេត្តគៀនយ៉ាង ប្រទេសវៀតណាមកាលពីថ្ងៃទី១៩-២០ ខែសីហា ឆ្នាំ២០១៩ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៨,១១ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

២.សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស៊ុន ហៅសាយ និងកំបាំងមុខដើមបណ្តឹងឈ្មោះ [redacted] ស្រីមៅ ហៅពេជ្រ និងឈ្មោះ [redacted] សារ៉ាន ទុកពេលប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ក្រុមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ០៦រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

កំពត,ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner